ទីស្តីការក្រសួងយុត្តិធម៌

លេខ ០៣ រប ៦១០៦-៩៤

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### ផ្ញើចំពោះ

**លោកប្រធានតុលាការ គ្រប់ខេត្ត ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** ករណីឃុំខ្លួនពិរុទ្ធជនហួសចិរវេលាកំណត់នៃច្បាប់ ។

**យោង:** បទបញ្ញត្តិនៃមានត្រា២៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ២១ ក្រ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ និងតាមបទបញ្ញត្តិនៃមាត្រា១៤ ចំណុចទី៤ នៃច្បាប់ស្តីពីប្រព័ន្ធតុលាការក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ។

ក្រោយពីបានពិនិត្យរឿងប្រហ្មទណ្ឌប្រចាំខែ និងរបាយការណ៍ត្រួតពិនត្យពន្ធនាគារប្រចាំខែ ក្រសួងយុត្តិធម៌សង្កេតឃើញថា ចៅក្រមនៃតុលាការខេត្ត ក្រុងជាច្រើនបានឃុំខ្លួនពិរុទ្ធជនហួសចិរវេលាកំណត់ ។ការធ្វើនេះផ្ទុយនិងបទបញ្ញត្តិនៃច្បាប់ដែលយោងខាងលើពោលគឺឃុំខ្លួនជនត្រូវចោទមុនពេលជំនុំជម្រះយ៉ាងយូរត្រឹមតែ៦ខែប៉ុណ្ណោះ។

ម្យ៉ាងទៀតក្រសួងបានសង្កេតឃើញថា មានសំណុំរឿងជាច្រើនកកស្ទះតាំងពីយូរឆ្នាំមកហើយដែលបានអនុវត្តតាមនីតិវិធីចាស់ ហើយតុលាការពុំទាន់បានជំនុំជម្រះនៅឡើយ ។ឯការឃុំខ្លួនជនល្មើសក៏ហួសចិរវេលាកំណត់នៃច្បាប់ ហើយលែងស្របនឹងច្បាប់បច្ចុប្បន្នទៀតផង ។

ចំពោះបញ្ហានេះ តុលាការអាចសើរើអនុវត្តតាមបទបញ្ញត្តិនៃមាត្រា៦៧ ដែលចែងថាព្រះរាជអាជ្ញា នឹងអាចប្រើនីតិវិធីចោទប្រកាន់ផ្ទាល់ទៅតុលាការតែម្តង ក្នុងករណីដែលជនជាប់ចោទត្រូវផ្តន្ទាទោសដាក់គុកជាអតិបរមានៃទោសមិនលើសពីមួយឆ្នាំ ។បើពុំនោះទេ ព្រះរាជអាជ្ញាត្រូវបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេតសិន ។

ចំពោះរឿងដែលមានមនុស្សជាប់ឃុំឃាំងជាយូរមកហើយ ហើយសំណុំរឿងត្រូវបាត់បង់ដោយមូលហេតុផ្សេងៗ នោះព្រះរាជអាជ្ញាត្រូវបង្កសំណុំរឿងឡើងវិញជាបន្ទាន់ ហើយធ្វើការចោទប្រកាន់បញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបអង្កេតណាដើម្បីធ្វើការស៊ើបអង្កេតដាក់ជូនតុលាការជំនុំជម្រះ ។

ខ្ញុំសូមលោកប្រធានតុលាការ និងព្រះរាជអាជ្ញាជំរុញចៅក្រមស៊ើបអង្កេត ចៅក្រមជំនុំជម្រះ និងព្រះរាជអាជ្ញារងទាំងអស់ ឲ្យយកចិត្តទុកដាក់ខ្លាំងបំផុត និងជាបន្ទាន់ក្នុងស្មារតីទទួលខុសត្រូវចំពោះមុខច្បាប់ដែលលើកឡើងពីការមិនគោរពបទបញ្ញត្តិខាងលើនេះ ហើយត្រូវផ្តន្ទាទោស ។

ក្រសួងយុត្តិធម៌សង្ឃឹមថា សេចក្តីណែនាំខាងលើនេះនឹងជៀសវាងផលវិបាកអាក្រក់ចំពោះចៅក្រម និងព្រះរាជអាជ្ញា ដែលមានការធ្វេសប្រហែស ។

ក្នុងករណីមានជួបការលំបាកសូមលោកលើកមតិសួរមកក្រសួងយុត្តិធម៌ ដើម្បីក្រសួងមានវិធានការណែនាំបន្ថែម ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ប្រធានតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-ប្រធានសាលាឧទ្ធរណ៍

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ប្រធានតុលាការយោធា

-ព្រះរាជអាជ្ញាអមតុលាការយោធា

-ដើម្បីជូនជ្រាប